ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបណ្តាប្រទេសអារ៉ាប់

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបណ្តាប្រទេសអារ៉ាប់មានចំនួន ១ ដូចមានរាយនាមក្នុងតារាងខាងក្រោម៖

| ល.រ. | ឈ្មោះក្រុមហ៊ុន | អាសយដ្ឋាន | លេខទូរសព្ទ |
|---|---|---|---|
| 1 | **ផេស៊ីហ្វិក អ៊ីមផ្លយម៉ិន អេជេន ខ.ក** PACIFIC EMPLOYMENT AGENT CO., LTD. | ផ្ទះលេខ១៥H ផ្លូវលេខ៣៧១ ភូមិទ្រា៣ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | 016 770 870<br>077 770 870<br>066 770 870 |

សាធារណជនដែលមានបំណងស្វែងរកការងារធ្វើនៅបណ្តាប្រទេសអារ៉ាប់ អាចចុះឈ្មោះស្វែងរកការងារដោយទាក់ទងផ្ទាល់ជាមួយទីភ្នាក់ងារជ្រើសរើសឯកជនដែលមានឈ្មោះក្នុងបញ្ជីខាងលើ ឬបញ្ជីបច្ចុប្បន្នភាពទីភ្នាក់ងារជ្រើសរើសឯកជននៅលើគេហទំព័រផ្លូវការរបស់ក្រសួងតាមរយៈតំណភ្ជាប់ www.mlvt.gov.kh ។

អ្នកស្វែងរកការងារធ្វើនៅក្រៅប្រទេស ក៏អាចចុះឈ្មោះស្វែងរកការងារតាមរយៈកម្មវិធីទូរសព្ទដៃរបស់ក្រសួង "MLVT Services" ឬតាម "បញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" ដែលមាននៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលការងារ សាខាបេឡាជាតិសន្តិសុខសង្គម គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្សារទំនើបអេអនទាំង៣សាខា ឬស្កេនយូអរកូដ "ការងារក្រៅប្រទេស" និងតាមដានដំណើរការឯកសាររបស់ខ្លួន ចាប់ពីដំណាក់កាលចុះឈ្មោះស្វែងរកការងារតាមរយៈតំណភ្ជាប់ https://tracking.ocwc.co/ ។

ទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើនេះ ជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ដែលត្រូវប្រឈមនឹងការផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ក្នុងករណីទទួលព័ត៌មានថាមានទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើ ធ្វើសកម្មភាពផ្សព្វផ្សាយជ្រើសរើសពលករទៅធ្វើការនៅបណ្តាប្រទេស



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

អារ៉ាប់ សូមរាយការណ៍ជាបន្ទាន់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធឆ្លើយតបបន្ទាន់ ១២៩៧ ឬក្រុមតេឡេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" តាមតំណភ្ជាប់ https://t.me/KhmerMigrantWorker ឬប្រអប់បណ្តឹងអនាមិកដោយស្កេនឃ្យូអរកូដខាងក្រោម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំង២៥ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសអ្នកដែលមានបំណងស្វែងរកការងារធ្វើនៅបណ្តាប្រទេសអារ៉ាប់ និងបណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២៦

"MLVT Services"

"ការងារក្រៅប្រទេសស្របច្បាប់"

"សម្រាប់ ពលករទេសន្តរប្រវេសន៍"

"បណ្តឹងអនាមិក"